ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល



# គោលការណ៍ណែនាំ ស្តីពី
# ការផ្តល់ និងការគ្រប់គ្រងថវិកាសម្រាប់ដំណើរការ
# អភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី

កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ)

២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល

# គោលការណ៍ណែនាំ

# ស្តីពី

# ការផ្តល់ និងការគ្រប់គ្រងថវិកាសម្រាប់ដំណើរការ អភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ

កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ)

២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

ថ្ងៃចន្ទ ១៣កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីសំណើសុំពិនិត្យ និងឯកភាពដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការផ្តល់ និងការគ្រប់គ្រងថវិកាសម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី។

**យោង៖** - កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងលេខ ACA/2018/041-466 និង ACA/2019/041-594 ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប។
- លិខិតលេខ ៦១១៨ កសក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនយល់ទាស់ទេចំពោះសំណើរៀបចំ និងអនុវត្តឯកសារប្រតិបត្តិ រួមមានគោលការណ៍ណែនាំស្តីពីការផ្តល់ និងការគ្រប់គ្រងថវិកាសម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី សម្រាប់អនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ) ដោយអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (SOPs) ជាធរមាន។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចាត់ចែងតាមការគួរ។
សូមឯកឧត្តមទទួលនូវគារវកិច្ច ពីខ្ញុំ។

**ជ.ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការប្រចាំការ**

**វង្សី វិស្សុត**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

# មាតិកា


**បញ្ជីតារាង និងដ្យាក្រាម ............ ៤**

**បញ្ជីតារាងឧបសម្ព័ន្ធ ............ ៤**

**១. សេចក្តីផ្តើម ............ ៥**

**២. និយមន័យ គោលបំណង ប្រភពធនធាន និងដំណើរការរួម នៃការអនុវត្ត ............ ៥**

២.១ និយមន័យ ............ ៥

២.២ គោលបំណង នៃថវិកាដែលផ្តល់ជូន ............ ៦

២.៣ ប្រភពធនធាន ............ ៦

២.៤ ដំណើរការរួមនៃការអនុវត្ត ............ ៧

**៣. ការជ្រើសរើសសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ............ ៧**

**៤. ការរៀបចំ និងការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ............ ៩**

៤.១ ដំណើរការរួមនៃការរៀបចំ និងការអនុម័ត ............ ៩

៤.២ ការរៀបចំសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដោយសហគមន៍ ............ ៩

៤.២.១ នីតិវិធីក្នុងការរៀបចំ ............ ៩

៤.២.២ មុខសញ្ញា និងកម្រិតចំណាយ ............ ១០

៤.២.៣ ការគ្រោងចំណាយប្រចាំឆមាស ............ ១០

៤.៣ ការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ............ ១០

៤.៣.១ ការត្រួតពិនិត្យលម្អិតដោយខណ្ឌរដ្ឋបាលជលផល ............ ១១

៤.៣.២ ការត្រួតពិនិត្យលើអនុលោមភាពដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ............ ១១

៤.៣.៣ ការត្រួតពិនិត្យ និងអនុម័តលើសំណើថវិកាសរុបដោយរដ្ឋបាលជលផល ............ ១១

៤.៤ កិច្ចព្រមព្រៀងរវាងខណ្ឌរដ្ឋបាលជលផល និងសហគមន៍ ............ ១២

៤.៤.១ ការចុះកិច្ចព្រមព្រៀង ............ ១២

៤.៤.២ ការកែសម្រួលលើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ............ ១២

**៥. ដំណើរការនៃការផ្ទេរថវិកា ............ ១២**

៥.១ លំហូរថវិកាពីថ្នាក់ជាតិ ទៅថ្នាក់សហគមន៍ ............ ១២

៥.២ លក្ខខណ្ឌនៃការផ្ទេរថវិកាប្រចាំឆមាស ............ ១៣

**៦. ការអនុវត្ត និងគ្រប់គ្រងថវិកានៅសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ............ ១៣**

៦.១ ការបើក និងការគ្រប់គ្រងគណនីធនាគាររបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ............ ១៤

៦.២ លក្ខខណ្ឌក្នុងការចំណាយប្រចាំឆមាស ............ ១៥

៦.៣ នីតិវិធីចំណាយថវិកា ............ ១៥

៦.៣.១ នីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន ............ ១៦

៦.៣.២ នីតិវិធីសម្រង់តម្លៃចំនួនបី ............ ១៦

៦.៣.៣ ការដេញថ្លៃជាចំហ ............ ១៧

៦.៤ របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ............ ១៨


sp.

៦.៤.១ សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី........................................................១៨

៦.៤.២ ខណ្ឌរដ្ឋបាលជលផល ........................................................................................១៨

៦.៤.៣ ការបញ្ឈប់ ឬការផ្អាកការផ្តល់ថវិកាគាំទ្រដល់សហគមន៍ ............................................១៨

**៧. ការអភិវឌ្ឍសមត្ថភាព ការតាមដាន និងវាយតម្លៃប្រចាំឆ្នាំ និងនិរន្តរភាព ..................................១៩**

៧.១ ការអភិវឌ្ឍសមត្ថភាព និងការត្រួតពិនិត្យតាមដាន .........................................................១៩

៧.២ និរន្តរភាព និងផែនការសម្រាប់រយៈពេលមធ្យម ដល់រយៈពេលវែង ......................................១៩

**៨. ឧបសម្ព័ន្ធ៖ ទម្រង់សម្រាប់ប្រើប្រាស់ ................................................................................ ២០**

## បញ្ជីតារាង និងដ្យាក្រាម


តារាងទី ១៖ លក្ខខណ្ឌ និងនីតិវិធីចំណាយ ............................................................................. ១៥
តារាងទី ២៖ ជំហានលម្អិតនៃនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន ..................................................... ១៦
តារាងទី ៣៖ ជំហានលម្អិតនៃនីតិវិធីចំណាយសម្រង់តម្លៃចំនួន៣ ........................................................... ១៦

ដ្យាក្រាមទី ១៖ ដំណើរការរួមនៃការអនុវត្តថវិកាសម្រាប់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី............. ៧
ដ្យាក្រាមទី ២៖ ដំណើរការនៃការរៀបចំ និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ... ៩
ដ្យាក្រាមទី៣៖ ដំណើរការនៃការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស ឆ្នាំរបស់សហគមន៍ .............. ១០
ដ្យាក្រាមទី ៤៖ លំហូរថវិកាពីថ្នាក់ជាតិ ទៅថ្នាក់សហគមន៍ ............................................................ ១៣
ដ្យាក្រាមទី ៥៖ លក្ខខណ្ឌ និងនីតិវិធីសំខាន់ៗក្នុងការចំណាយថវិកា............................................... ១៤


## បញ្ជីតារាងឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១៖ លក្ខណៈវិនិច្ឆ័យសម្រាប់បជ្រើសរើសសហគមន៍នេសាទ .........................................២០
ឧបសម្ព័ន្ធទី ២៖ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសសហគមន៍ស្រះជម្រកត្រី.....................................២៣
ឧបសម្ព័ន្ធទី ៣៖ កិច្ចព្រមព្រៀងរវាងខណ្ឌរដ្ឋបាលជលផល និងសហគមន៍ ......................................២៦
ឧបសម្ព័ន្ធទី ៤៖ ផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ...................................២៩
ឧបសម្ព័ន្ធទី ៥៖ ឧទាហរណ៍នៃផែនការសកម្មភាពនិងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ........................ ៣០
ឧបសម្ព័ន្ធទី ៦៖ សំណើសរុបនៃផែនការ និងថវិកាសម្រាប់ដាក់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ .......... ៣១
ឧបសម្ព័ន្ធទី ៧៖ សំណើសរុបនៃផែនការ និងថវិកាសម្រាប់ដាក់ជូនរដ្ឋបាលជលផល.................................៣២
ឧបសម្ព័ន្ធទី ៨៖ របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាសរបស់សហគមន៍............................៣៣
ឧបសម្ព័ន្ធទី៩៖ របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាសរបស់ខណ្ឌរដ្ឋបាលជលផល............... ៣៥
ឧបសម្ព័ន្ធទី ១០៖ របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆ្នាំរបស់សហគមន៍...............................៣៧
ឧបសម្ព័ន្ធទី ១១៖ របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆ្នាំរបស់ខណ្ឌរដ្ឋបាលជលផល................. ៣៩
ឧបសម្ព័ន្ធទី ១២៖ លិខិតផ្ទេរសិទ្ធិ ............................................................................................៤១
ឧបសម្ព័ន្ធទី ១៣៖ ការស្នើសុំ និងការអនុម័តលើសំណើចំណាយតាមរដ្ឋទេយ្យបុរេប្រទាន...............................៤២
ឧបសម្ព័ន្ធទី ១៤៖ ការទូទាត់ និងការអនុម័តលើការទូទាត់ចំណាយតាមរដ្ឋទេយ្យបុរេប្រទាន .......................... ៤៣
ឧបសម្ព័ន្ធទី ១៥៖ វិក្កយបត្រសម្រាប់ប្រើផ្ទៃក្នុង សម្រាប់ការចំណាយតាមរដ្ឋទេយ្យបុរេប្រទាន .........................៤៤
ឧបសម្ព័ន្ធទី ១៦៖ ប័ណ្ណចំណាយ ...............................................................................................៤៥
ឧបសម្ព័ន្ធទី ១៧៖ សៀវភៅតាមដានសាច់ប្រាក់...................................................................................៤៦
ឧបសម្ព័ន្ធទី ១៨៖ ការស្នើសុំ និងការអនុម័តយល់ព្រមលើការទិញទំនិញ សេវាកម្ម ....................................... ៤៧
ឧបសម្ព័ន្ធទី ១៩៖ សម្រង់តម្លៃទំនិញទាំង៣ និងការអនុម័តយល់ព្រម..................................................៤៨
ឧបសម្ព័ន្ធទី ២០៖ ការទូទាត់ និងការអនុម័តលើការចំណាយទិញទំនិញ....................................................៤៩
ឧបសម្ព័ន្ធទី ២១៖ បញ្ជីសារពើភ័ណ្ឌ.............................................................................................៥០

## ១. សេចក្តីផ្តើម

យោងច្បាប់ស្តីពីជលផលឆ្នាំ២០០៦ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទឆ្នាំ២០០៧ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ឆ្នាំ២០១៥-២០២៤ រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយដៃគូអភិវឌ្ឍន៍ បានសម្រេចផ្តល់ថវិកាប្រចាំឆ្នាំ សម្រាប់ដំណើរការនិងគាំទ្រដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ចាប់ពីឆ្នាំ២០២១ នេះតទៅ។

ដើម្បីគាំទ្រដល់ការអនុវត្តការផ្តល់ថវិកាខាងលើ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដើម្បីសម្រេចនូវគោលបំណងដូចខាងក្រោម៖

- បង្កើត និងចង្អុលបង្ហាញអំពីដំណើរការក្នុងការផ្តល់ និងការគ្រប់គ្រងថវិកា ដែលត្រូវផ្ទេរពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ទៅឱ្យសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ស្របតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងសមត្ថភាពជាក់ស្តែងរបស់សហគមន៍
- ផ្តល់ការណែនាំអំពីនីតិវិធី និងទម្រង់រដ្ឋបាលដែលត្រូវប្រើ ជាពិសេសនៅថ្នាក់រាជធានី ខេត្ត និងនៅថ្នាក់សហគមន៍ក្នុងការរៀបចំផែនការសកម្មភាព ការរៀបចំនិងអនុម័តថវិកា ការអនុវត្តថវិកា និងការរៀបចំរបាយការណ៍លើការអនុវត្តថវិកាដែលបានផ្ទេរ
- ជំរុញឱ្យមានការទទួលបានថវិកាប្រកបដោយសមធម៌នៃសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ជាពិសេសសម្រាប់សហគមន៍ដែលមិនមានការគាំទ្រច្រើន និងសមត្ថភាពនៅមានកម្រិត។

គោលការណ៍ណែនាំស្តីពីការផ្តល់ និងការគ្រប់គ្រងថវិកាសម្រាប់ដំណើរការសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ត្រូវបានរៀបចំ ស្របតាមវិធានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជាពិសេស ស្របតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលឃុំ-សង្កាត់ ដែលមានកិច្ចការ និងសមត្ថភាពគ្រប់គ្រងថវិកាប្រហាក់ប្រហែលនឹងស្ថានភាពនៅសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីផងដែរ។

គោលការណ៍ណែនាំនេះ នឹងត្រូវអនុវត្តដោយ៖

- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខណ្ឌរដ្ឋបាលជលផល
- សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ដែលទទួលបានថវិកា ត្រូវទទួលខុសត្រូវចំពោះការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

## ២. និយមន័យ គោលបំណង ប្រភពធនធាន និងដំណើរការរួមនៃការអនុវត្ត

### ២.១ និយមន័យ

ថវិកាសម្រាប់ដំណើរការ និងគាំទ្រដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីនៅកម្ពុជា គឺជាថវិកាប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលនឹងផ្តល់ជូនសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការជ្រើសរើស ដូចចែងនៅក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ។



ទ

ថវិកាសម្រាប់ដំណើរការ និងគាំទ្រសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ត្រូវកំណត់នូវកម្រិតអតិបរមា និងអប្បបរមា យោងតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ថវិកាសម្រាប់ដំណើរការ និងគាំទ្រសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ត្រូវផ្ទេរទៅក្នុងគណនីរបស់សហគមន៍នៅធនាគារ។

សមតុល្យថវិកាចុងឆ្នាំ (ថវិកានៅសល់ចុងឆ្នាំ) ដែលមាននៅក្នុងគណនីរបស់សហគមន៍ ត្រូវផ្ទេរទៅឆ្នាំបន្ទាប់។

ចំពោះសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីដែលមិនអាចអនុវត្តសកម្មភាពការងារ និងថវិកា ដែលបានផ្តល់ជូន ត្រូវផ្ទេរថវិកាដែលនៅសល់មករដ្ឋបាលជលផលវិញ ដើម្បីបិទបញ្ចប់គម្រោង។

## ២.២ គោលបំណងនៃថវិកាដែលផ្តល់ជូន

ថវិកាប្រចាំឆ្នាំដែលត្រូវផ្តល់ មានគោលបំណងគាំទ្រដំណើរការ និងការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី យោងតាមផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដែលសហគមន៍នីមួយៗបានស្នើសុំ ត្រូវបានអនុម័ត។

សហគមន៍អាចប្រើប្រាស់ថវិកាដែលបានផ្តល់សម្រាប់ទ្រទ្រង់ដំណើរការ និងការអភិវឌ្ឍន៍ ដូចខាងក្រោម ៖

- ការងារការិយាល័យ ការធ្វើដំណើរ និងការឧបត្ថម្ភសម្រាប់ សមាជិក បុគ្គលិក ឬជំនួយការ
- ការថែរក្សា
- ការកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- សកម្មភាពផ្សេងទៀតដែលចាំបាច់ក្នុងការងារអភិវឌ្ឍន៍សហគមន៍។

## ២.៣ ប្រភពធនធាន

ប្រភពថវិកាសម្រាប់ដំណើរការ និងគាំទ្រដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីរួមមាន៖

- ចំណូលចរន្ត នៃថវិការដ្ឋ
- ដៃគូអភិវឌ្ឍន៍ ក្រោមក្របខ័ណ្ឌហិរញ្ញប្បទាន និងកិច្ចសហប្រតិបត្តិការ
- ប្រភពផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

ប្រភពថវិការដ្ឋប្រចាំឆ្នាំ នឹងត្រូវអនុម័តដោយរាជរដ្ឋាភិបាល សម្រាប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ។

ថវិកាសម្រាប់ដំណើរការសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ជាផ្នែកមួយនៃថវិការបស់រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការកំណត់ថវិកានេះ អាចនឹងពិចារណាធ្វើការផ្លាស់ប្តូរទៅតាមការចាំបាច់ ដោយអនុលោមតាមគោលការណ៍នៃកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាល។[1]

[1] ទិសដៅនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ មានចែងនៅក្នុង៖ ១) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ២) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។



SP

ដោយអនុលោមតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុក្នុងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវជានាការផ្តល់ថវិកាដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ត្រូវបានផ្សារភ្ជាប់ និងស្របតាមផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធីរបស់ក្រសួង និងអនុវិស័យ រួមទាំងការរៀបចំ និងការអនុវត្តថវិកា។

ករណីមានការចូលរួមពីដៃគូអភិវឌ្ឍន៍ នីតិវិធីក្នុងការទទួលហិរញ្ញប្បទាន ត្រូវអនុវត្តតាមនីតិវិធី កិច្ចសន្យាហិរញ្ញប្បទាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

## ២.៤ ដំណើរការរួមនៃការអនុវត្ត

គោលការណ៍ណែនាំនេះផ្តោតលើវដ្តទាំងមូលនៃការអនុវត្តថវិកាសម្រាប់ដំណើការ និងគាំទ្រដល់សហគមន៍ ចាប់ពីការជ្រើសរើសសហគមន៍ ការកសាងសមត្ថភាព ការតាមដាន ការត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងផែនការបន្តនិរន្តរភាព។ ដំណើរការរួមនេះ មានបង្ហាញក្នុងដ្យាក្រាមខាងក្រោម។

គោលការណ៍ណែនាំ ចង្អុលបង្ហាញអំពីនីតិវិធីដំណើរការ វិធីសាស្ត្រ ក៏ដូចជាទម្រង់រដ្ឋបាលដែលត្រូវប្រើ សម្រាប់ជំហាននីមួយៗ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ។[2]

**ដ្យាក្រាមទី ១៖ ដំណើរការរួមនៃការអនុវត្តថវិកាសម្រាប់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី**




## ៣. ការជ្រើសរើសសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី

ចំពោះសហគមន៍នេសាទដែលនឹងត្រូវជ្រើសរើស ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- បានចុះបញ្ជីជាផ្លូវការ
- មិនមានជម្លោះទាក់ទងនឹងកម្មសិទ្ធិ និងព្រំប្រទល់ ជាមួយភាគីពាក់ព័ន្ធ
- មានកន្លែងអភិរក្សត្រីមេពូជសហគមន៍ ដែលកំពុងដំណើរការយ៉ាងតិចណាស់ ០១កន្លែង
- មានគណៈកម្មការគ្រប់គ្រង ស្របតាមនីតិវិធី និងច្បាប់ជាធរមាន
- បានរៀបចំផែនការគ្រប់គ្រង ឬផែនការសកម្មភាព និងថវិកាសម្រាប់សហគមន៍របស់ខ្លួន
- មិនមានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងតម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាកន្លងមក។

---

[2]ភាគច្រើននៃទម្រង់ដែលត្រូវប្រើប្រាស់សម្រាប់ដំណើការថវិកាសម្រាប់ដំណើរការនិងគាំទ្រដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ដែលមានបង្ហាញក្នុងឯកសារនេះ ត្រូវបានយោងតាមប្រកាសពាក់ព័ន្ធនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះសហគមន៍ស្រះជម្រកត្រីដែលនឹងត្រូវជ្រើសរើស ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- សហគមន៍ត្រូវបានទទួលស្គាល់ជាផ្លូវការ
- មិនមានជម្លោះទាក់ទងនឹងកម្មសិទ្ធិ ព្រំប្រទល់ ការប្រើប្រាស់វាលស្រែ និងការប្រើប្រាស់ទឹកជាមួយភាគីពាក់ព័ន្ធនានា
- មានកន្លែងអភិរក្សត្រីមេពូជ យ៉ាងហោចណាស់មួយ
- បានរៀបចំជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍រួចរាល់ តាមនីតិវិធីជាធរមាន
- មានផែនការគ្រប់គ្រង ឬផែនការសកម្មភាព និងថវិកាសម្រាប់សហគមន៍
- មិនមានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងតម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាកន្លងមក។

សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ដែលធ្លាប់ ឬកំពុងទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក៏នៅតែអាចទទួលបានការគាំទ្រតាមរយៈការផ្តល់ថវិកាខ្នាតតូចនេះដែរ។ ជាមួយគ្នានេះ ដោយឈរលើគោលការណ៍សមធម៌ ការជ្រើសរើសសហគមន៍ នឹងផ្តល់អាទិភាពចំពោះសហគមន៍ដែលទទួលបានការគាំទ្រតិចតួចពីប្រភពផ្សេង ឬសហគមន៍ដែលមានសមត្ថភាពនៅមានកម្រិត ដោយផ្តល់ជូនដល់សហគមន៍ទាំងនោះនូវការកសាងសមត្ថភាព និងការគាំទ្របច្ចេកទេសតាមការចាំបាច់។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម មានតួនាទីសម្របសម្រួល ក្នុងការជ្រើសរើសសហគមន៍ ដោយសហការជាមួយខណ្ឌរដ្ឋបាលជលផលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្តពាក់ព័ន្ធ។ ខណ្ឌរដ្ឋបាលជលផល នឹងរៀបចំគណៈកម្មការសម្របសម្រួលមួយ ដែលនឹងត្រូវសម្រេចតែងតាំងដោយប្រធានមន្ទីកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដើម្បីជ្រើសរើសសហគមន៍តាមខេត្តរបស់ខ្លួន ដោយយោងតាមលក្ខណសម្បត្តិសំខាន់ៗខាងលើ ដោយប្រើតារាងដាក់ពិន្ទុលម្អិត ដូចមានក្នុងឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី២។

សមាសភាពរបស់គណៈកម្មការសម្របសម្រួល គួរមានការចូលរួមពីស្ត្រីយ៉ាងហោច១នាក់។ ចំនួន និងសមាសភាពគណៈកម្មការសម្របសម្រួល រួមមាន៖

- នាយខណ្ឌរដ្ឋបាលជលផល ជាប្រធាន
- នាយរងខណ្ឌរដ្ឋបាលជលផល ជាអនុប្រធាន
- មន្ត្រីជំនាញខណ្ឌរដ្ឋបាលជលផលចំនួន៣រូប ជាសមាជិក (តែងតាំងដោយនាយខណ្ឌរដ្ឋបាលជលផល)។

ការវាយតម្លៃជ្រើសរើសសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ត្រូវធ្វើឡើងដោយគណៈកម្មការសម្របសម្រួល តាមរយៈការចុះសម្ភាសន៍ ការចុះពិនិត្យទីតាំង និងការប្រើប្រាស់វិធីសាស្ត្រដាក់ពិន្ទុ ផ្អែកតាមគោលការណ៍ដែលបានរៀបរាប់ខាងលើ និងតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២។

ពិន្ទុដែលបានផ្តល់ដោយសមាជិកគណៈកម្មការសម្របសម្រួលម្នាក់ៗនឹងត្រូវបូកសរុប ដើម្បីប្រៀបធៀបរវាងសហគមន៍មួយទៅសហគមន៍មួយទៀត ដោយជ្រើសរើសយកសហគមន៍ដែលទទួលបានពិន្ទុខ្ពស់តាមលំដាប់លំដោយទៅតាមចំនួនសហគមន៍ដែលបានកំណត់តាមខេត្តនីមួយៗ។



SP

# ៤. ការរៀបចំ និងការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍

## ៤.១ ដំណើរការរួមនៃការរៀបចំ និងការអនុម័ត

បន្ទាប់ពីត្រូវបានជ្រើសរើស សហគមន៍ត្រូវរៀបចំសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដើម្បីទទួលបានថវិកាក្នុងការអនុវត្តគម្រោងនៅសហគមន៍។ ដំណើរការរួមនៃការរៀបចំ និងការអនុម័តសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ មានបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖

**ដ្យាក្រាមទី២ ៖ ដំណើរការនៃការរៀបចំ និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍**




## ៤.២ ការរៀបចំសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដោយសហគមន៍

បន្ទាប់ពីត្រូវបានជ្រើសរើស សហគមន៍ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆមាស និងប្រចាំឆ្នាំរបស់ខ្លួន ដោយអនុវត្តតាមនីតិវិធី និងវិធីសាស្ត្រដូចខាងក្រោម៖

### ៤.២.១ នីតិវិធីក្នុងការរៀបចំ

ការរៀបចំសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវមានការចូលរួមពីសមាជិកសហគមន៍ និងត្រូវអនុម័តដោយគណៈកម្មការគ្រប់គ្រងសហគមន៍ យោងតាមវិធាននិងបទបញ្ញត្តិផ្ទៃក្នុង និងនីតិវិធីជាធរមាន។ គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល មានតួនាទីផ្តល់ការគាំទ្របច្ចេកទេសដល់សហគមន៍ក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់ខ្លួន។

ក្នុងករណីចាំបាច់ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្មអាចផ្តល់ជាជំនួយបច្ចេកទេសដល់សហគមន៍។

គណៈកម្មការសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ត្រូវដាក់ជូនផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដែលបានអនុម័ត មកគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល។

សហគមន៍ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ តាមទម្រង់ដែលបានផ្តល់ជូនក្នុងឧបសម្ព័ន្ធទី ៤ នៃគោលការណ៍ណែនាំនេះ។

### ៤.២.២ មុខសញ្ញា និងកម្រិតចំណាយ

ផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដែលសហគមន៍ត្រូវរៀបចំ និងដាក់ស្នើទៅខណ្ឌរដ្ឋបាលជលផល ត្រូវឆ្លុះបញ្ចាំងពីបញ្ហាអាទិភាពដែលមានកំណត់ក្នុងផែនការគ្រប់គ្រង និងត្រូវស្របតាមតម្រូវការជាក់ស្តែងរបស់សហគមន៍។

សហគមន៍ត្រូវគ្រោងចំណាយថវិកាសរុបប្រចាំឆ្នាំរបស់ខ្លួន មិនឱ្យលើសពីកញ្ចប់ថវិកាដែលបានអនុម័ត និងជូនដំណឹងដោយរដ្ឋបាលជលផល។ សហគមន៍ត្រូវគ្រោងចំណាយប្រចាំឆ្នាំទៅតាមមុខសញ្ញា និងកម្រិតចំណាយ ដូចខាងក្រោម៖

- *ចំណាយដំណើរការរដ្ឋបាល* មិនលើសពី២៥% នៃថវិកាប្រចាំឆ្នាំ
- *ចំណាយការងារអភិវឌ្ឍន៍* មិនទាបជាង៧៥% នៃថវិកាប្រចាំឆ្នាំ។

### ៤.២.៣ ការគ្រោងចំណាយប្រចាំឆមាស

សម្រាប់មុខសញ្ញានីមួយៗ សហគមន៍ត្រូវបែងចែកគម្រោងចំណាយប្រចាំឆ្នាំរបស់ខ្លួន ទៅជាគម្រោងចំណាយប្រចាំឆមាស ដោយគោរពតាមលក្ខខណ្ឌខាងក្រោម៖

- *ចំណាយដំណើរការរដ្ឋបាល* មិនលើសពី២៥% នៃថវិកាដែលផ្ទេរប្រចាំឆមាស
- *ចំណាយលើការងារអភិវឌ្ឍន៍* អាចគ្រោងទៅតាមតម្រូវការជាក់ស្តែង និងនៅក្នុងរង្វង់ថវិកា ដែលនៅសល់ បន្ទាប់ពីដកចេញចំណាយដំណើរការរដ្ឋបាល។

សូមមើលឧបសម្ព័ន្ធទី ៥ សម្រាប់ឧទាហរណ៍នៃការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដែលសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីត្រូវរៀបចំ។

## ៤.៣ ការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍

**សំណើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី នឹងត្រូវអនុម័តដោយអនុវត្តតាមជំហាន ដូចបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖**

**ដ្យាក្រាមទី៣៖ ដំណើរការនៃការអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ របស់សហគមន៍**



### ៤.៣.១ ការត្រួតពិនិត្យលម្អិតដោយខណ្ឌរដ្ឋបាលជលផល

គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល ត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការត្រួតពិនិត្យលម្អិតទៅលើសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ដោយអនុវត្តតាមវិធីសាស្ត្រខាងក្រោម៖

- បញ្ជាក់ថាសហគមន៍បានអនុវត្តតាមនីតិវិធី និងវិធីសាស្ត្រដែលបានចែងខាងលើ នៅក្នុងការរៀបចំ និងអនុម័តសំណើផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់ខ្លួនដែរឬទេ?
- ពិនិត្យលើសកម្មភាព និងថវិកាដែលបានស្នើសុំ តើឆ្លើយតបទៅនឹងតម្រូវការ បញ្ហាប្រឈម ឬ អាទិភាពដូចមានចែងនៅក្នុងផែនការគ្រប់គ្រងរបស់សហគមន៍ដែរឬទេ?
- ក្នុងករណីសំណើរបស់សហគមន៍ មិនចំទិសដៅ ឬមិនស្របតាមតម្រូវការរបស់សហគមន៍ គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល ត្រូវរួសរាន់ទំនាក់ទំនង និងពិភាក្សាជាមួយសហគមន៍ ដើម្បីធ្វើការកែសម្រួលឱ្យទាន់ពេលវេលាក្នុងការអនុវត្តគម្រោង។

### ៤.៣.២ ការត្រួតពិនិត្យអនុលោមភាពដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បន្ទាប់ពីធ្វើការត្រួតពិនិត្យ និងយល់ព្រម ខណ្ឌរដ្ឋបាលជលផល ត្រូវរៀបចំសំណើសរុបប្រចាំខេត្ត និងភ្ជាប់ជាមួយផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍នីមួយៗ ដាក់ជូនប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីត្រួតពិនិត្យលើអនុលោមភាព[3]នៃសំណើនោះ។ សូមប្រើទម្រង់ក្នុងឧបសម្ព័ន្ធទី៦ ដើម្បីរៀបចំសំណើសរុបប្រចាំរាជធានី ខេត្ត។

ដោយមានការគាំទ្របច្ចេកទេសពីខណ្ឌរដ្ឋបាលជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវត្រួតពិនិត្យ ដើម្បីធានាទាំងសំណើសរុប និងសំណើរបស់សហគមន៍នីមួយៗ បានអនុលោមតាមនីតិវិធីពាក់ព័ន្ធ ដូចមានចែងនៅក្នុងគោលការណ៍ណែនាំនេះ។[4]

ក្នុងករណីរកឃើញមានការខ្វះខាតលើការអនុវត្តនីតិវិធី ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការជាមួយសហគមន៍ពាក់ព័ន្ធ ដើម្បីធ្វើការកែសម្រួល មុននឹងដាក់ជូនប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការត្រួតពិនិត្យសារជាថ្មី។

### ៤.៣.៣ ការត្រួតពិនិត្យ និងអនុម័តលើសំណើថវិកាសរុបដោយរដ្ឋបាលជលផល

បន្ទាប់ពីអនុម័តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំសំណើសរុបប្រចាំខេត្តនៃផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំនៃសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី រួចផ្ញើជូនរដ្ឋបាលជលផល តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ប្រើប្រាស់ទម្រង់ដែលមាននៅក្នុងឧបសម្ព័ន្ធទី ៧) ។

រដ្ឋបាលជលផលត្រូវពិនិត្យ និងអនុម័តលើផែនការសកម្មភាព និងថវិកាសរុបរបស់សហគមន៍តាមខេត្តនីមួយៗ ដោយផ្អែកតាមនីតិវិធីដែលមានចែងនៅក្នុងគោលការណ៍ណែនាំនេះ។

---

[3] ក្នុងការត្រួតពិនិត្យអនុលោមភាព ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោតលើតែភាពត្រឹមត្រូវលើគោលការណ៍ និងនីតិវិធី សំខាន់ៗ ដោយមិនផ្តោតលើទិដ្ឋភាពលម្អិតឡើយ។

[4] នីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនេះ បានយោងតាមគោលការណ៍ប្រហាក់ប្រហែលគ្នានឹង ប្រកាសលេខ ២៨០៩ ប្រក ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិកម្មអំណាចដល់អភិបាលខេត្តក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក។

៤.៤ កិច្ចព្រមព្រៀងរវាងខណ្ឌរដ្ឋបាលជលផល និងសហគមន៍

### ៤.៤.១ ការចុះកិច្ចព្រមព្រៀង

បន្ទាប់ពីសំណើនៃផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ត្រូវបានអនុម័តដោយរដ្ឋបាលជលផល គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំកិច្ចព្រមព្រៀងជាមួយសហគមន៍ ដោយប្រើទម្រង់ដែលមាននៅក្នុងឧបសម្ព័ន្ធទី៣។ កិច្ចព្រមព្រៀងត្រូវផ្ញើទៅសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីនីមួយៗ ដើម្បីពិនិត្យ និងផ្ទៀតផ្ទាត់សកម្មភាពគម្រោង ថវិកា និងលក្ខខណ្ឌតម្រូវផ្សេងៗ។

កិច្ចព្រមព្រៀងត្រូវរៀបចំ និងចុះហត្ថលេខាដោយប្រធានគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល និងប្រធានគណៈកម្មការសហគមន៍នេសាទ ឬសហគមន៍ស្រះជម្រកត្រី ដោយមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធជាសាក្សី។

ដើម្បីធានានូវតម្លាភាព ព័ត៌មានអំពីសកម្មភាព និងថវិកាដែលបានអនុម័តនៅក្នុងកិច្ចព្រមព្រៀង ត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍។

### ៤.៤.២ ការកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍

បន្ទាប់ពីការចុះកិច្ចព្រមព្រៀង និងនៅក្នុងដំណាក់កាលនៃការអនុវត្តការងារ រាល់ការកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំរបស់សហគមន៍ ដូចជាគោលបំណង ទីតាំង និងមុខសញ្ញានៃការចំណាយ ត្រូវមានការឯកភាពជាលាយលក្ខណ៍អក្សរ រវាងគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល និងសហគមន៍សាមី។

គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផលរាជធានី ខេត្ត ត្រូវឆ្លើយតបក្នុងរយៈពេលពីរសប្ដាហ៍ ចាប់ពីពេលទទួលបានការស្នើសុំកែតម្រូវពីសហគមន៍។

## ៥. ដំណើរការនៃការផ្ទេរថវិកា

៥.១ លំហូរថវិកាពីថ្នាក់ជាតិ ទៅថ្នាក់សហគមន៍

សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីត្រូវបើកគណនីសន្សំនៅធនាគារ ដើម្បីទទួលថវិកាដែលនឹងត្រូវផ្ទេរ។ នីតិវិធីលម្អិតសម្រាប់ការបើក និងគ្រប់គ្រងគណនី មានចែងនៅក្នុងផ្នែកបន្ទាប់។

ថវិកាត្រូវផ្ទេរពីថ្នាក់ជាតិ ទៅក្នុងគណនីរបស់សហគមន៍ ទៅតាមលំហូរដូចមានបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖



SP.

**ដ្យាក្រាមទី៤ ៖ វិហ្គូរថវិកាពីថ្នាក់ជាតិ ទៅថ្នាក់សហគមន៍**

១. ថវិកាផ្ទេរពីសហភាពអឺរ៉ុប ឬដៃគូអភិវឌ្ឍន៍ទៅកាន់ក្រសួង សហវ តាមរយៈធនាគារជាតិ

២. ប្រចាំឆមាស ក្រសួង សហវ ផ្ទេរថវិកាទៅក្នុងគណនីរបស់រដ្ឋបាលជលផល

៣. ប្រចាំឆមាស រដ្ឋបាលជលផល ផ្ទេរថវិកាទៅ គណនីរបស់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី (នៅដើមឆមាស ឱ្យឆាប់តាមដែលអាចធ្វើបាន)

៤.សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី ចំណាយថវិកាដើម្បីអនុវត្តផែនការដែលបានអនុម័ត

វិហ្គូរថវិកាពីសហភាពអឺរ៉ុប ឬដៃគូអភិវឌ្ឍន៍នានាទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។

ជារៀងរាល់ឆមាស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្ទេរសាច់ប្រាក់ទៅក្នុងគណនីរបស់រដ្ឋបាលជលផល ដែលបានបើកនៅធនាគារសម្រាប់ថវិកាគាំទ្រ។ ការផ្ទេរប្រាក់ត្រូវធ្វើឡើងនៅដើមឆមាសនីមួយៗ ឱ្យបានឆាប់តាមដែលអាចធ្វើបាន។

ជារៀងរាល់ឆមាស រដ្ឋបាលជលផលត្រូវផ្ទេរថវិកាទៅក្នុងគណនីរបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ដែលបានបើកនៅធនាគារ។ ការផ្ទេរថវិកា ត្រូវធ្វើនៅដើមឆមាសនីមួយៗ ឱ្យឆាប់តាមដែលអាចធ្វើបាន។

ការផ្ទេរថវិកាពីខណ្ឌរដ្ឋបាលជលផលទៅគណនីរបស់សហគមន៍សម្រាប់ឆមាសនីមួយៗ មានចំនួនស្មើនឹង៥០% នៃថវិកាប្រចាំឆ្នាំសរុបដែលត្រូវបានអនុម័ត។

## ៥.២ លក្ខខណ្ឌនៃការផ្ទេរថវិកាប្រចាំឆមាស

ដើម្បីធានាបាននូវភាពរលូននៃការផ្ទេរថវិកា រាល់ការផ្ទេរប្រចាំឆមាសពីរដ្ឋបាលជលផលទៅគណនីរបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីនឹងត្រូវធ្វើជាប្រចាំ ដោយមិនមានភ្ជាប់លក្ខខណ្ឌនៃការអនុម័តលើសំណើសុំថវិកា និងរបាយការណ៍ចំណាយសម្រាប់ឆមាសមុនឡើយ។

ទន្ទឹមនេះ ដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ថវិកា សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាស និងប្រចាំឆ្នាំ រួចធ្វើជូនគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល និងត្រូវរក្សាទុកឯកសារយុត្តិការដែលចាំបាច់ សម្រាប់ការត្រួតពិនិត្យ និងធ្វើសវនកម្មនៅពេលក្រោយ។ សូមមើលផ្នែកទី ៦.៤ សម្រាប់ព័ត៌មានបន្ថែម។

## ៦. ការអនុវត្ត និងគ្រប់គ្រងថវិកានៅសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី

ដំណើរការនៃការចំណាយ និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ចាំបាច់ត្រូវអនុវត្តភារកិច្ច និងនីតិវិធីជាក់លាក់ ដូចដ្យាក្រាមខាងក្រោម។

**ដ្យាក្រាមទី ៥៖ លក្ខខណ្ឌ និងនីតិវិធីសំខាន់ៗក្នុងការចំណាយថវិកា**

| ការបើក និងការគ្រប់គ្រងគណនីធនាគារ | លក្ខខណ្ឌក្នុងការចំណាយប្រចាំឆមាស | នីតិវិធីចំណាយ | ការកត់ត្រាទុកក្នុងសៀវភៅជាប្រចាំ និងរាយការណ៍ |
|---|---|---|---|
| •ការបើកគណនីសន្សំ<br>•ការអនុវត្តវិធានស្ដីពីការប្រើប្រាស់គណនីសន្សំ | •សម្រាប់ចំណាយដំណើរការរដ្ឋបាល<br>•សម្រាប់ចំណាយការងារអភិវឌ្ឍន៍ | •ការចំណាយតាមរដ្ឋទេយ្យបុរេប្រទាន<br>•ការធ្វើលទ្ធកម្មជាមួយការសម្រង់តម្លៃចំនួន ៣<br>•ការដេញថ្លៃជាសាធារណៈ | •ការគ្រប់គ្រងសាច់ប្រាក់ និងគណនីធនាគារ<br>• ការកត់ត្រាទុកក្នុងសៀវភៅតាមដានសាច់ប្រាក់<br>•ការកត់ត្រាសៀវភៅបញ្ជីសារពើភណ្ឌ |

## ៦.១ ការបើក និងការគ្រប់គ្រងគណនីធនាគាររបស់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី

បន្ទាប់ពីត្រូវបានជ្រើសរើស សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ត្រូវបើកគណនីនៅធនាគារ ដើម្បីទទួលថវិកា ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

- ឈ្មោះរបស់គណនីធនាគារដែលត្រូវបើក គឺជាឈ្មោះរបស់សហគមន៍នេសាទ ឬសហគមន៍ស្រះជម្រកត្រី និងជាប្រភេទគណនីសន្សំ
- ការប្រាក់ដែលទទួលបាន និងការកើនឡើងនៃប្រាក់សន្សំត្រូវចាត់ទុកជាចំណូលសម្រាប់សហគមន៍
- គណនីត្រូវបើកជាប្រាក់រៀល ប៉ុន្តែការចំណាយអាចធ្វើជាប្រាក់ដុល្លារ ឬប្រាក់រៀល តាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ
- សហគមន៍អាចចំណាយថវិកានៅក្នុងគណនីរបស់ខ្លួន ដោយប្រាក់សុទ្ធ ឬផ្ទេរតាមធនាគារ
- អ្នកដែលមានសិទ្ធិចុះហត្ថលេខាក្នុងការដកប្រាក់ ឬលើមូលប្បទានប័ត្រ (សែក) គឺជាប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មការសហគមន៍ដែលទទួលការផ្ទេរសិទ្ធិ
- ការប្រើគណនីសម្រាប់ការងារផ្ទាល់ខ្លួន និងការដកប្រាក់ដោយប្រើម៉ាស៊ីន អេ ធី អ៊ឹម (ATM) ត្រូវហាមឃាត់
- សហគមន៍មិនអាចចំណាយ ឬដកសាច់ប្រាក់ ដោយទុកឱ្យសាច់ប្រាក់នៅក្នុងគណនីស្មើសូន្យ ឬទាបជាងចំនួនតម្រូវជាអប្បបរមារបស់ធនាគារបានឡើយ
- បេឡាករសហគមន៍ មានតួនាទីរក្សាទុកសាច់ប្រាក់ដែលបានដកមកពីធនាគារ ដោយការទទួលខុសត្រូវ
- ក្នុងករណីចាំបាច់ សហគមន៍អាចជ្រើសរើសអ្នកស្ម័គ្រចិត្ត អ្នកហាត់ការ ឬមន្ត្រីកិច្ចសន្យាដែលមានជំនាញមូលដ្ឋានទាក់ទងនឹងការងារថវិកា និងការប្រើកុំព្យូទ័រ ដើម្បីជួយការងារនិងគ្រប់គ្រងថវិការបស់សហគមន៍
- បេឡាករមិនអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់លើសពី ២,០០០,០០០រៀល (ពីរលានរៀល) ក្នុងដៃឡើយ ដើម្បីហេតុផលសុវត្ថិភាព
- រាល់ការដក និងការចំណាយសាច់ប្រាក់ ត្រូវមានការកត់ត្រាចូលក្នុងសៀវភៅតាមដានសាច់ប្រាក់ក្នុងដៃ (ប្រើទម្រង់ក្នុងឧបសម្ព័ន្ធទី១៧)
- នៅចុងខែនីមួយៗ សហគមន៍នឹងទទួលបានរបាយការណ៍ពីធនាគារ ដែលបញ្ជាក់ពីចំនួនទឹកប្រាក់ដែលបានចំណាយ និងចំនួននៅសល់។

## ៦.២ លក្ខខណ្ឌក្នុងការចំណាយប្រចាំឆមាស

សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីដែលទទួលបានថវិកា ត្រូវអនុវត្តការចំណាយប្រចាំឆមាសរបស់ខ្លួនទៅតាមផែនការសកម្មភាព និងថវិកាប្រចាំឆមាស ឆ្នាំ ដែលត្រូវបានអនុម័ត។

ក្នុងករណីតម្រូវឱ្យមានការចំណាយខុសពីផែនការដែលបានអនុម័ត លក្ខខណ្ឌខាងក្រោមត្រូវបានអនុវត្តៈ

- *ចំណាយដំណើរការរដ្ឋបាល* សហគមន៍អាចធ្វើការកែប្រែមុខសញ្ញា និងទំហំចំណាយ តែមិនឱ្យលើសពី២៥% នៃថវិកាដែលផ្ទេរប្រចាំឆមាស។
- *ចំណាយការងារអភិវឌ្ឍន៍*៖
  - សហគមន៍អាចធ្វើការកែប្រែទំហំ និងកាលបរិច្ឆេទចំណាយ សម្រាប់មុខសញ្ញាចំណាយ
  - ប្រសិនបើមានការកែប្រែមុខសញ្ញាចំណាយ សហគមន៍ត្រូវស្នើសុំយោបល់ និងការយល់ព្រមជាលាយលក្ខណ៍អក្សរពីគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល។ គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផលត្រូវឆ្លើយតបក្នុងរយៈពេល ២សប្តាហ៍ បន្ទាប់ពីទទួលបានការស្នើសុំ។

## ៦.៣ នីតិវិធីចំណាយថវិកា

ដូចបានរៀបរាប់ខាងដើម សហគមន៍នេសាទ ឬសហគមន៍ស្រះជម្រកត្រី អាចចំណាយថវិកាលើការងាររដ្ឋបាល និងការងារអភិវឌ្ឍន៍។ កម្រិតតម្លៃក្នុងការចំណាយ ឬក្នុងវិក្កយបត្រត្រូវបានប្រើដើម្បីកំណត់នីតិវិធីសមស្របសម្រាប់ការចំណាយ និងការទូទាត់នីមួយៗ ដូចសង្ខេបក្នុងតារាងទី១ខាងក្រោម។

**តារាងទី១ ៖ លក្ខខណ្ឌ និងនីតិវិធីចំណាយ**

| មុខសញ្ញាចំណាយ | សកម្មភាពទូទៅ | កម្រិតតម្លៃក្នុងមួយទំនិញ/វិក្កយបត្រ[5] | នីតិវិធីចំណាយ | ការចំណាយ |
|---|---|---|---|---|
| ការងាររដ្ឋបាលទូទៅ | -ប្រតិបត្តិការការិយាល័យ<br>-ការប្រជុំ<br>-ប្រាក់ឧបត្ថម្ភ | < ៥០០,០០០ រៀល | ចំណាយតាមរង្វាន់ទេយ្យបុរេប្រទាន | ប្រាក់សុទ្ធ |
| ការងារប្រតិបត្តិការ និងថែទាំ | -ការល្បាត<br>-បុគ្គលិក<br>-ទំនិញ និងសេវាកម្ម<br>-សម្ភារសម្រាប់កំណត់ ព្រំប្រទល់<br>-ការសាងសង់តូច តម្លៃក្រោម២លានរៀល | < ៥០០,០០០ រៀល | ចំណាយតាមរង្វាន់ទេយ្យបុរេប្រទាន | ប្រាក់សុទ្ធ |
| | | ៥០០,០០០ -២,០០០,០០០ រៀល | សម្រង់តម្លៃចំនួន៣ | ប្រាក់សុទ្ធ |
| ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | -គម្រោងសាងសង់ | >២,០០០,០០០រៀល | ការដេញថ្លៃជាចំហរ | ការផ្ទេរតាមធនាគារ |

---

[5] យោងតាមប្រកាសរបស់ក្រសួង សហវ ស្តីពីនីតិវិធីប្រទាន និងលទ្ធកម្មសាធារណៈ



៩

### ៦.៣.១ នីតិវិធីចំណាយតាមរង្វេទយ្យបុរេប្រទាន

ប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញ(ដូចក្នុងតារាងទី១) ការចំណាយអាចធ្វើទៅបានដោយប្រើនីតិវិធីចំណាយតាមរង្វេទយ្យបុរេប្រទាន ដូចបានបង្ហាញក្នុងតារាងទី២។

**តារាងទី២ ៖ ជំហានលម្អិតនៃនីតិវិធីចំណាយតាមរង្វេទយ្យបុរេប្រទាន**

| ជំហាន | សកម្មភាពចម្បង | ឧបសម្ព័ន្ធ |
|---|---|---|
| ជំហានទី ១ | ការរៀបចំសំណើ និងអនុម័តចំណាយតាមរង្វេទយ្យបុរេប្រទាន៖<br>- សមាជិកសហគមន៍ធ្វើសំណើសុំសាច់ប្រាក់ដើម្បីចំណាយ<br>- បេឡាករត្រួតពិនិត្យ និងបញ្ជូនសំណើសុំទៅប្រធានសហគមន៍<br>- ប្រធានសហគមន៍ ឬអនុប្រធានទទួលបានការផ្ទេរសិទ្ធិ ត្រួតពិនិត្យ និងអនុម័តលើសំណើ។ | ឧបសម្ព័ន្ធទី ១៣ |
| ជំហានទី ២ | ការទូទាត់ការចំណាយ និងប្រមូលវិក្កយបត្រ៖<br>- បេឡាករប្រគល់ប្រាក់ជូនសមាជិកសហគមន៍ និងកត់ត្រាលើប័ណ្ណចំណាយ<br>- បេឡាករកត់ត្រាវិហរចេញនៃសាច់ប្រាក់ ទៅក្នុងសៀវភៅតាមដានសាច់ប្រាក់<br>- សមាជិកសហគមន៍ត្រូវប្រមូលវិក្កយបត្រពីអ្នកទទួលប្រាក់ អ្នកផ្គត់ផ្គង់ ឬប្រើប្រាស់វិក័យបត្រផ្ទៃក្នុង (ប្រសិនអ្នកផ្គត់ផ្គង់មិនអាចចេញវិក្កយបត្របាន)។ | ឧបសម្ព័ន្ធទី ១៦<br>ឧបសម្ព័ន្ធទី ១៧<br>ឧបសម្ព័ន្ធទី ១៥ |
| ជំហានទី ៣ | ការទូទាត់ការចំណាយតាមរង្វេទយ្យបុរេប្រទាន៖<br>- សមាជិកសហគមន៍បញ្ជូនឯកសារទូទាត់ការចំណាយតាមរង្វេទយ្យបុរេប្រទានទៅបេឡាករ<br>- បេឡាករត្រួតពិនិត្យ និងបញ្ជូនឯកសារទូទាត់ចំណាយ ទៅប្រធានសហគមន៍ដើម្បីពិនិត្យ និងអនុម័ត<br>- ប្រធានសហគមន៍ ឬអនុប្រធានទទួលបានការផ្ទេរសិទ្ធិ ពិនិត្យ និងអនុម័តឯកសារ។ | ឧបសម្ព័ន្ធទី ១៤ |

### ៦.៣.២ នីតិវិធីសម្រង់តម្លៃចំនួនបី

ប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញ (ដូចក្នុងតារាងទី ១) ការចំណាយអាចធ្វើទៅបាន ដោយប្រើនីតិវិធីសម្រាប់សម្រង់តម្លៃចំនួន៣ ដូចបានបង្ហាញក្នុងតារាងទី ៣។

**តារាងទី៣ ៖ ជំហានលម្អិតនៃនីតិវិធីចំណាយសម្រង់តម្លៃចំនួន៣**

| ជំហាន | សកម្មភាពចម្បង | ឧបសម្ព័ន្ធ |
|---|---|---|
| ជំហានទី ១ | ការរៀបចំសំណើ និងអនុម័តលើទំនិញ ឬសេវាកម្ម៖<br>- សមាជិកសហគមន៍ស្នើសុំទិញទំនិញ ឬសេវាកម្ម<br>- បេឡាករពិនិត្យ និងបញ្ជូនសំណើទៅប្រធានសហគមន៍ | ឧបសម្ព័ន្ធទី ១៨ |

| | | |
|---|---|---|
| | - ប្រធានសហគមន៍ ឬអនុប្រធានទទួលបានការផ្ទេរសិទ្ធិ ពិនិត្យ និងអនុម័តសំណើ។ | |
| ជំហានទី ២ | <u>ការទទួលបានសម្រង់តម្លៃចំនួន៣ និងការជ្រើសរើសអ្នកផ្គត់ផ្គង់៖</u><br>- បេឡាករប្រមូលសម្រង់តម្លៃចំនួន៣ និងបញ្ជូនទៅគណៈកម្មការលទ្ធកម្ម<br>- គណៈកម្មការលទ្ធកម្មប្រជុំជ្រើសរើសអ្នកផ្គត់ផ្គង់ដែលសមស្រប<br>- ក្នុងករណីពិបាកក្នុងការស្វែងរកសម្រង់តម្លៃទាំង៣ ការទិញដោយផ្ទាល់ត្រូវបានអនុញ្ញាត។ ក្នុងករណីនេះ ត្រូវមានលិខិតបញ្ជាក់មូលហេតុសមស្រប និងចុះហត្ថលេខាដោយប្រធានសហគមន៍ ឬអនុប្រធានទទួលបានការផ្ទេរសិទ្ធិ។ | ឧបសម្ព័ន្ធទី ១៩ |
| ជំហានទី ៣ | <u>ការទិញទំនិញ ឬសេវាកម្ម៖</u><br>- បេឡាករចំណាយប្រាក់ឱ្យអ្នកផ្គត់ផ្គង់ជាសាច់ប្រាក់ និងប្រមូលវិក្កយបត្រ<br>- បេឡាករប្រើប័ណ្ណចំណាយដើម្បីកត់ត្រាការបង់ប្រាក់<br>- បេឡាករកត់ត្រាលំហូរសាច់ប្រាក់ចេញក្នុងសៀវភៅកត់ត្រាសាច់ប្រាក់។ | ឧបសម្ព័ន្ធទី ១៦<br>ឧបសម្ព័ន្ធទី ១៧ |
| ជំហានទី ៤ | <u>ការទូទាត់ចំណាយ និងការកត់ត្រាក្នុងសៀវភៅសារពើភ័ណ្ឌ៖</u><br>- បេឡាកររៀបចំ និងបញ្ជូនការទូទាត់ចំណាយជូនប្រធានសហគមន៍ ឬអនុប្រធានទទួលបានការផ្ទេរសិទ្ធិ ដើម្បីអនុម័ត<br>- បេឡាករកត់ត្រាទំនិញដែលបានទិញក្នុងសៀវភៅសារពើភណ្ឌ។ | ឧបសម្ព័ន្ធទី ២០<br>ឧបសម្ព័ន្ធទី ២១ |

គួរកត់សម្គាល់ថា សហគមន៍ត្រូវបង្កើតគណៈកម្មការលទ្ធកម្ម ដើម្បីធ្វើការសម្រេចចិត្តលើការជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយប្រើនីតិវិធីសម្រង់តម្លៃចំនួន៣ ។

សមាសភាពគណៈកម្មការលទ្ធកម្ម រួមមាន៖

- ប្រធានសហគមន៍
- សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ចំនួន០២ (ពីរ)រូប
- បេឡាករ។

ក្នុងករណីដែលសម្លេងនៃការបោះឆ្នោតស្មើគ្នា សន្លឹកឆ្នោតរបស់ប្រធានសហគមន៍ គឺជាសម្លេងចុងក្រោយ ដើម្បីសម្រេចជ្រើសរើសយកអ្នកផ្គត់ផ្គង់នោះ។

### ៦.៣.៣ ការដេញថ្លៃជាសាធារណៈ

ប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញ (ដូចក្នុងតារាងទី១) ដំណើរការដេញថ្លៃជាសាធារណៈ នឹងត្រូវធ្វើឡើង។ ដោយមិនរំពឹងថាសហគមន៍នឹងត្រូវការប្រើនីតិវិធីដេញថ្លៃនេះនាពេលអនាគតចំពោះមុខ ព័ត៌មានលម្អិតនៃនីតិវិធីនេះមិនត្រូវបានដាក់បញ្ចូលក្នុងគោលការណ៍ណែនាំនេះទេ។ ក្នុងករណីចាំបាច់ នីតិវិធីនៃការដេញថ្លៃដូចមានចែងក្នុងគោលការណ៍ណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (ឆ្នាំ២០១៧) នឹងត្រូវយកមកអនុវត្ត។



៩

## ៦.៤ របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ

### ៦.៤.១ សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី

សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ដែលទទួលបានថវិកាគាំទ្រ ត្រូវរៀបចំរបាយការណ៍ជូនគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល តាមទម្រង់ និងតាមការកាលបរិច្ឆេទ ដូចខាងក្រោម៖

- របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាស (តាមទម្រង់ក្នុងឧបសម្ព័ន្ធទី៨) ត្រូវធ្វើឱ្យបានមុនថ្ងៃទី១៥ នៃខែទីមួយនៃឆមាសបន្ទាប់
- របាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆ្នាំ (តាមទម្រង់ក្នុងឧបសម្ព័ន្ធទី ១០) ត្រូវធ្វើឱ្យបានមុនរយៈពេល ១៥ ថ្ងៃ ក្រោយថ្ងៃដែលត្រូវបញ្ចប់ការអនុវត្តគម្រោងប្រចាំឆ្នាំ។

សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ត្រូវរក្សាទុកឯកសារយុត្តិការនានា សម្រាប់ការត្រួតពិនិត្យ និងសវនកម្ម ដែលនឹងត្រូវអនុវត្ត ក្រោយពេលចំណាយ។

### ៦.៤.២ ខណ្ឌរដ្ឋបាលជលផល

ខណ្ឌរដ្ឋបាលជលផល តាមរយៈគណៈកម្មការសម្របសម្រួល ត្រូវធ្វើរបាយការណ៍វឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាស និងប្រចាំឆ្នាំ ដាក់ជូនរដ្ឋបាលជលផលតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមទម្រង់ និងកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍សរុបវឌ្ឍនភាពការងារ និងចំណាយប្រចាំឆមាស (តាមទម្រង់ក្នុងឧបសម្ព័ន្ធទី ៩) ត្រូវធ្វើឱ្យបានមុនថ្ងៃទី៣០ នៃខែទីមួយនៃឆមាសបន្ទាប់
- របាយការណ៍សរុបវឌ្ឍនភាពការងារ និងចំណាយប្រចាំឆ្នាំ (តាមទម្រង់ក្នុងឧបសម្ព័ន្ធទី ១១) ត្រូវធ្វើឱ្យបានមុនថ្ងៃទី ២៨ ខែកុម្ភៈនៃឆ្នាំបន្ទាប់។

ខណ្ឌរដ្ឋបាលជលផលត្រូវរក្សាទុកឯកសារយុត្តិការនានា សម្រាប់ត្រួតពិនិត្យ និងសវនកម្ម ដែលអាចនឹងត្រូវធ្វើឡើង ក្រោយពេលចំណាយ។

### ៦.៤.៣ ការបញ្ឈប់ ឬការផ្អាកការផ្តល់ថវិកាគាំទ្រដល់សហគមន៍

សម្រាប់សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រីដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬគ្មានសមត្ថភាពក្នុងការបន្តអនុវត្តការងារ ដោយប្រើថវិកាគាំទ្របន្តទៀត សហគមន៍សាមីត្រូវផ្ទេរថវិកាដែលនៅសល់ជូនមករដ្ឋបាលជលផលវិញ តាមរយៈគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល និងត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរដែលមិនអាចអនុវត្តសកម្មភាពការងារបាន។

ខណ្ឌរដ្ឋបាលជលផល នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវមានឯកសារយោងបញ្ជាក់ពីមូលហេតុជាក់លាក់ និងត្រូវធ្វើការផ្ទេរថវិកាដែលនៅសល់មករដ្ឋបាលជលផលវិញ ដើម្បីបិទបញ្ចប់គម្រោង។ ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការជាមួយសហគមន៍សាមី ដើម្បីធានាថាថវិកាដែលនៅសល់ត្រូវបានផ្ទេរពីគណនីធនាគាររបស់សហគមន៍សាមីមកគណនីធនាគាររបស់រដ្ឋបាលជលផលវិញ។

## ៧. ការអភិវឌ្ឍសមត្ថភាព ការតាមដាន និងវាយតម្លៃប្រចាំឆ្នាំ និងនិរន្តរភាព

### ៧.១ ការអភិវឌ្ឍសមត្ថភាព និងការត្រួតពិនិត្យតាមដាន

មន្ត្រីពាក់ព័ន្ធនៅរដ្ឋបាលជលផល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផល និងសហគមន៍ នឹងត្រូវបានបណ្តុះបណ្តាលអំពីដំណើរការ និងនីតិវិធីនៃការអនុវត្តគោលការណ៍ណែនាំនេះ។ រដ្ឋបាលជលផល ដែលមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម មានតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំ និងសម្របសម្រួលការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធ និងសហគមន៍គោលដៅ។

គណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល និងរដ្ឋបាលជលផល ដែលមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នឹងចុះតាមដាន និងត្រួតពិនិត្យ ការអនុវត្តគម្រោងតាមបណ្តារាជធានី ខេត្ត និងជ្រើសរើសតំបន់គោលដៅសហគមន៍ ដើម្បីធ្វើឱ្យប្រាកដថា សហគមន៍បានអនុវត្តតាមសកម្មភាពតាមផែនការការងារ និងទទួលបានលទ្ធផលតាមការរំពឹងទុក និងផ្តល់នូវអនុសាសន៍ពាក់ព័ន្ធសម្រាប់ការកែលម្អ។

លើសពីនេះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នឹងសហការជាមួយគណៈកម្មការសម្របសម្រួលនៃខណ្ឌរដ្ឋបាលជលផល ដើម្បីធ្វើការវាយតម្លៃប្រចាំឆ្នាំ ដោយមានការចូលរួមពីសហគមន៍ដែលបានទទួលថវិកាគាំទ្រ ដើម្បីរៀនសូត្រពីបទពិសោធន៍ ការរីកចម្រើន ផ្តល់អនុសាសន៍ និងការលើកទឹកចិត្តបន្ថែមទៀតដល់សហគមន៍ដែលមានស្នាដៃ។

### ៧.២ និរន្តរភាព និងផែនការរយៈពេលមធ្យម ឬរយៈពេលវែង

ដើម្បីធានាបាននូវភាពជាម្ចាស់ និងនិរន្តរភាពរបស់សហគមន៍ ក្នុងរយៈពេលមធ្យម ឬរយៈពេលវែង គួរពិចារណានូវទិសដៅអនាគតចំនួន៣ ដូចខាងក្រោម៖

- ជំរុញការធ្វើវិសហមជ្ឈការថវិកា ដោយអនុញ្ញាតឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអង្គភាពថវិកាធ្វើគម្រោងបែងចែក តាមដាន និងត្រួតពិនិត្យថវិកាដែលត្រូវផ្តល់ជូនសហគមន៍នេសាទ និងសហគមន៍ជម្រកត្រី (សម្រាប់រយៈពេលមធ្យម)
- ការផ្ទេរមុខងារដើម្បីគាំទ្រដល់សហគមន៍ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលក្រុង និងស្រុក) រួមទាំងថវិកា ធនធានមនុស្ស និងទ្រព្យសម្បត្តិ ស្របតាមកំណែទម្រង់វិមជ្ឈការរបស់រាជរដ្ឋាភិបាល (សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង),
- ជំរុញ និងលើកកម្ពស់សមត្ថភាពរបស់សហគមន៍ ក្នុងការរកប្រាក់ចំណូលផ្ទាល់ (ឧ. ពីថ្លៃសេវាកម្ម ឬការចូលរួមចំណែករបស់សមាជិក) និងធ្វើការគ្រប់គ្រងចំណូលទាំងនោះប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។



SP

## ៨. ឧបសម្ព័ន្ធ៖ ទម្រង់សម្រាប់ប្រើប្រាស់

### ឧបសម្ព័ន្ធទី១ ៖ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសសហគមន៍នេសាទ

**ឈ្មោះសហគមន៍នេសាទ៖**..........................................................................**លេខកូដ:**..........................

**ភូមិ:**..............................**ឃុំ:**..............................**ស្រុក៖** ...............**ខេត្ត:**..........................................

| លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើស | ចម្លើយ | | |
|---|---|---|---|
| | បាទ | ទេ | ផ្សេងៗ |
| **១.ស្ថានភាពផ្លូវច្បាប់** | | | |
| ១.១.តើសហគមន៍នេសាទត្រូវបានចុះបញ្ជីជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទហើយ ឬនៅ? | | | |
| ១.២.តើសហគមន៍នេសាទមានផែនការគ្រប់គ្រង ឬផែនការសកម្មភាព និងថវិកាហើយ ឬនៅ? | | | |
| បើចម្លើយ បាទ នៅចំណុច (១.១) និង (១.២) ខាងលើ សូមបន្តសួរទៅសំណួរខាងក្រោម៖ | | | |
| | ពិន្ទុ | | |
| | ១ | ២ | ៣ |
| **២.ស្ថានភាពស្ថាប័នរបស់សហគមន៍នេសាទ** | | | |
| ២.១. រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ និងការគ្រប់គ្រង៖<br>- មិនទាន់បានបោះឆ្នោតជ្រើសរើសគណៈកម្មការ និងមិនមានសមាជិកពេញលេញនៅឡើយ (១)<br>- បានបោះឆ្នោតជ្រើសរើសគណៈកម្មការ មានសមាជិក មានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ប៉ុន្តែមិនបានអនុវត្តពេញលេញ (២)<br>- បានបោះឆ្នោតជ្រើសរើសគណៈកម្មការ មានសមាជិកគ្រប់ចំនួន មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង និងកំពុងអនុវត្តបានល្អ (៣) | | | |
| ២.២.គណៈកម្មការសហគមន៍នេសាទមានកិច្ចសហការល្អ និងមានការគាំទ្រ៖<br>- ពីអាជ្ញាធរមូលដ្ឋាន ឬពីអង្គការក្រៅរដ្ឋាភិបាល (១)<br>- ពីខណ្ឌរដ្ឋបាលជលផល វិស័យឯកជន និងសហគមន៍នានា (២)<br>- ពីអាជ្ញាធរមូលដ្ឋាន ខណ្ឌរដ្ឋបាលជលផល វិស័យឯកជន NGOs និងសហគមន៍នានា (៣) | | | |
| ២.៣. តើសហគមន៍នេសាទមានជម្លោះដែននេសាទកើតឡើងឬទេ? ដូចជា ជម្លោះព្រំប្រទល់ ដែននេសាទ តំបន់អភិរក្ស ការប្រើប្រាស់ទឹក ។ល។<br>- កំពុងមានជម្លោះ *(១)*<br>- មានជម្លោះ តែបានដោះស្រាយខ្លះៗហើយ *(២)*<br>- អត់មានជម្លោះ *(៣)* | | | |
| **សរុបពិន្ទុ (ចំណុច២)** | | | |



SP

| | | | |
|---|---|---|---|
| **៣. ស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់សហគមន៍នេសាទ** | | | |
| ៣.១.សហគមន៍នេសាទអាចផ្តល់ផលប្រយោជន៍ដល់សមាជិកសហគមន៍នេសាទដែលពឹងអាស្រ័យលើធនធានជលផលក្នុងសហគមន៍៖<br>- ផ្តល់បានតិចជាង៣៥% នៃចំនួនប្រជាជន (១)<br>- ផ្តល់បានពី ៣៥%-៧០ % នៃចំនួនប្រជាជន (២)<br>- ផ្តល់លើសពី ៧០% នៃចំនួនប្រជាជន (៣) | | | |
| ៣.២. គណនីធនាគារ បេឡាករ ឬគណនេយ្យករ និងសមត្ថភាពការងារគ្រប់គ្រងថវិកា៖<br>- មានបេឡា ឬគណនេយ្យករ ប៉ុន្តែមិនត្រូវបានប្រើប្រាស់ *(១)*<br>- មានគណនីធនាគារ បេឡាករ ឬគណនេយ្យករ និងបានប្រើប្រាស់ខ្លះៗ *(២)*<br>- មានគណនីធនាគារ បេឡាករ ឬគណនេយ្យករ និងសមត្ថភាពការងារ និងបានប្រើប្រាស់យ៉ាងល្អ *(៣)* | | | |
| ៣.៣.តើសហគមន៍នេសាទមានថវិកាផ្ទាល់ខ្លួនឯង និងបានទទួលការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ទេ?<br>- មានថវិកាផ្ទាល់ខ្លួនមួយចំនួន និងមានការគាំទ្រពីសប្បុរសជនច្រើនជាង៣ អង្គការក្រៅរដ្ឋាភិបាលដែលសរុបថវិកាមានច្រើនជាង ៤លានរៀល *(១)*<br>- មានថវិកាផ្ទាល់ខ្លួនមួយចំនួន និងមានការគាំទ្រថវិកាពីសប្បុរសជន និង១-៣ អង្គការក្រៅរដ្ឋាភិបាល សរុបថវិកាតិចជាង ៤លានរៀល *(២)*<br>- មិនមានថវិកាផ្ទាល់ខ្លួន និងគ្មានការគាំទ្រពីសប្បុរសជន និង អង្គការក្រៅរដ្ឋាភិបាលសោះ *(៣)* | | | |
| ៣.៤.ការចូលរួមរបស់ស្ត្រី<br>- គ្មានស្ត្រីក្នុងជួរគណៈកម្មការសហគមន៍នេសាទ *(១)*<br>- មានស្ត្រី១នាក់ក្នុងជួរគណៈកម្មការ *(២)*<br>- មានស្ត្រីចាប់ពី២នាក់ឡើងទៅក្នុងជួរគណៈកម្មការ *(៣)*. | | | |
| ៣.៥ ការចុះឈ្មោះចូលរៀនកូនរបស់គ្រួសារសហគមន៍នេសាទ<br>- បានចុះឈ្មោះកូនចូលរៀនពី ០% - ៣៥% (១)<br>- បានចុះឈ្មោះកូនចូលរៀនពី ៣៦% - ៧០% (២)<br>- បានចុះឈ្មោះកូនចូលរៀនលើសពី ៧០% (៣) | | | |
| **សរុបពិន្ទុ (៣)** | | | |
| **៤.ស្ថានភាព នៃការអភិរក្សធនធានជលផលរបស់សហគមន៍** | | | |
| ៤.១. តំបន់អភិរក្សរបស់សហគមន៍នេសាទ<br>-គ្មានកន្លែងអភិរក្ស *(១)*<br>-មានកន្លែងអភិរក្ស ប៉ុន្តែរីងស្ងួតនៅរដូវប្រាំង *(២)*<br>-មានកន្លែងអភិរក្ស និងមិនស្ងួតនៅរដូវប្រាំង *(៣)* | | | |
| ៤.២ តើតំបន់អភិរក្សសហគមន៍នេសាទមានការកែលម្អទេ? | | | |



sp.

| | | | |
|---|---|---|---|
| -មិនមានការរៀបចំផែនការអភិវឌ្ឍន៍កន្លែងអភិរក្សសហគមន៍ *(១)*<br>-មានផែនការអភិវឌ្ឍន៍កន្លែងអភិរក្ស និងបានអនុវត្តខ្លះៗ *(២)*<br>-រៀបចំផែនការអភិវឌ្ឍន៍កន្លែងអភិរក្ស និងបានអនុវត្តបានយ៉ាងល្អ ដូចជាបានបោះបង្គោល និងដាក់ជម្រកសិប្បនិម្មិត *(៣)* | | | |
| ៤.៣.ការយាម និងល្បាត<br>-មិនមានក្រុមល្បាត *(១)*<br>-មានក្រុមល្បាត និងចុះល្បាតតិចជាង២ដងក្នុងមួយខែ *(២)*<br>-មានក្រុមល្បាត មានកាលវិភាគចុះល្បាត និងចុះល្បាតច្រើនជាង២ដងក្នុងមួយខែ *(៣)* | | | |
| **សរុបពិន្ទុ (៤)** | | | |
| **សរុបពិន្ទុរួម (២+៣+៤)** | | | |
| **ការផ្ដល់អនុសាសន៍**<br>.............................................................................................................................<br>............................................................................................................................. | | | |

**សម្គាល់៖**

- ចំណាត់ថ្នាក់ពន្ទុ៖ ១= ខ្សោយ, ២= មធ្យម, ៣= ល្អ
- បើចម្លើយនៅចំណុច (១.១) និង (១.២) ទេ, មានន័យថាសហគមន៍នេសាទនេះត្រូវបានធ្លាក់ដោយស្វ័យប្រវត្តិ។
- បើចម្លើយនៅចំណុច (១.១) និង (១.២) បាទ ការជ្រើសរើស គឺរាប់យកពីពិន្ទុសរុបខ្ពស់មកទាប រហូតដល់គ្រប់ចំនួនសហគមន៍ដែលត្រូវបានកំណត់ ។

**ពិនិត្យដោយ** *(នាយខណ្ឌរដ្ឋបាលជលផល)*:.............................. **រៀបចំដោយ** *(ប្រធានក្រុមការងារ)*:..............................

**ថ្ងៃខែឆ្នាំ**:.............................................................. **ថ្ងៃខែឆ្នាំ**:..............................................................

## ឧបសម្ព័ន្ធទី២ ៖ លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសសហគមន៍ស្រះជម្រកត្រី

